# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន

## ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ

## និងជំនួយវេជ្ជសាស្ត្រ

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)

ចូល

លេខ [illegible]

ថ្ងៃទី 28.11.00 ម៉ោង 7:30

បញ្ជូនទៅ [illegible]


# ព្រះរាជក្រម

នស/រកម/១១០០/១០

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសម្តេចនាយករដ្ឋមន្ត្រី និង អំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ០២ ខែ សីហា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយ ដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើក ទី ៣ នីតិកាលទី ១ លើកលែងតែចំណុចទី៤នៃមាត្រាទី៣ ក្នុងជំពូកទី១ ប៉ុន្តែត្រូវបានរដ្ឋសភាធ្វើការបោះឆ្នោតអនុម័តជាចំហ ដោយមិនយល់ព្រមតាមសំណើរបស់ព្រឹទ្ធសភា នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០០ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់បែបបទនិងល័ក្ខខ័ណ្ឌនៃការប្រព្រឹត្តទៅសំរាប់ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ត្រូវបានចាត់ទុកជា :

-អ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនិងអមវេជ្ជសាស្ត្រ គឺ គ្រូពេទ្យ ឱសថការី ទន្តពេទ្យនិងឆ្មប ។

-អ្នកប្រកបវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រគឺ គិលានុបដ្ឋាក គិលានុបដ្ឋាយិកា អ្នកបច្ចេកទេសមន្ទីរពិសោធន៍ អ្នកព្យាបាលដោយចលនា អ្នកបច្ចេកទេសធ្មេញនិងអ្នកប្រកបវិជ្ជាជីវៈប្រហាក់ប្រហែលផ្សេងទៀត ។

មុខវិជ្ជាជីវៈប្រហាក់ប្រហែលដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣.-**

មានសិទ្ធិប្រកបវិជ្ជាជីវៈជាអ្នកវេជ្ជសាស្ត្រ អ្នកអមវេជ្ជសាស្ត្រនិងអ្នកជំនួយវេជ្ជសាស្ត្របាន ចំពោះជនណាដែលមានលក្ខណសម្បត្តិដូចខាងក្រោមនេះ :

-មានសញ្ជាតិខ្មែរ

-មានសញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល

-បានចុះឈ្មោះក្នុងបញ្ជីសមាជិកគណៈគ្រូពេទ្យ គណៈឱសថការី គណៈទន្តពេទ្យ គណៈឆ្មប គណៈគិលានុបដ្ឋាក·

-មិនដែលមានទោសពីបទល្មើសព្រហ្មទណ្ឌណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារនេះបាន ។

មាត្រា ៤.-

អាចអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ ជាអ្នកអមវេជ្ជសាស្ត្រនិងជាអ្នកជំនួយវេជ្ជសាស្ត្រដែលមានកំរិតជំនាញឯកទេសខ្ពស់ប្រកបវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។ បែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី២

## ការបើក ការកែទ្រង់ទ្រាយនិងការបិទសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

មាត្រា ៥.-

ការបើក ការកែទ្រង់ទ្រាយបន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺទន្តវេទនសាស្ត្រ (មាត់ធ្មេញ) បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់សោភ័ណសល្យសាស្ត្រ មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរសម្ភព មន្ទីរសំរាកព្យាបាលពហុព្យាបាល សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រឬជំនួយវេជ្ជសាស្ត្រឯកជនផ្សេងទៀត ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។ ក្រោយពីបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាលហើយ ត្រូវអនុវត្តតាមនីតិវិធីជាធរមាន។

ចំពោះការបិទវិញត្រូវសុំច្បាប់ពីក្រសួងសុខាភិបាល ។

មាត្រា ៦.-

អ្នកមានសិទ្ធិប្រកបវិជ្ជាជីវៈដូចមានចែងក្នុងមាត្រា ៣នៃច្បាប់នេះ អាចមានសិទ្ធិសុំបើក :

-បន្ទប់ពិគ្រោះព្យាបាលជំងឺឯកជនបាន ចំពោះតែវេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម

-បន្ទប់ពិគ្រោះព្យាបាលជំងឺទន្តវេទនសាស្ត្រ(មាត់ធ្មេញ)ឯកជនបាន ចំពោះតែទន្តបណ្ឌិត ទន្តពេទ្យ ឬគ្រូពេទ្យឯកទេសមាត់

-បន្ទប់ព្យាបាលដោយចលនាឯកជនបាន ចំពោះតែអ្នកព្យាបាលដោយចលនា

-បន្ទប់ថែទាំជំងឺឯកជនបានចំពោះតែគិលានុបដ្ឋាកមធ្យម ឬគិលានុបដ្ឋាយិ-

កាមធ្យម

-បន្ទប់សោភ័ណសល្យសាស្ត្រឯកជនបាន ចំពោះតែវេជ្ជបណ្ឌិតដែលមានឯកទេសជំនាញផ្នែកនេះ

-មន្ទីរពិសោធន៍វេជ្ជសាស្ត្រឯកជនបាន ចំពោះតែវេជ្ជបណ្ឌិត ឱសថបណ្ឌិត ឬឱសថការីឧត្តមដែលមានឯកទេសជំនាញមន្ទីរពិសោធន៍

-មន្ទីរសម្ភព មន្ទីរសំរាកព្យាបាលពហុព្យាបាលឯកជនបាន ចំពោះតែវេជ្ជបណ្ឌិត ។

ដោយឡែកចំពោះឆ្មបមធ្យមមានសិទ្ធិបើកតែបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះឯកជនប៉ុណ្ណោះ ។

## មាត្រា ៧.-

មន្ទីរសម្ភព មន្ទីរសំរាកព្យាបាលពហុព្យាបាលឯកជនទាំងឡាយដែលមានគ្រែសំរាប់អ្នកជំងឺសំរាកព្យាបាលនិងមន្ទីរពិសោធន៍វេជ្ជសាស្ត្រឯកជនត្រូវមានវត្តមានរបស់អ្នកទទួលខុសត្រូវ ។

ក្នុងករណីអវត្តមានអ្នកទទួលខុសត្រូវ ត្រូវមានអ្នកជំនួស ។ លក្ខណសម្បត្តិនៃអ្នកទទួលខុសត្រូវនិងអ្នកត្រូវជំនួស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## មាត្រា ៨.-

អ្នកវេជ្ជសាស្ត្រ អ្នកអមវេជ្ជសាស្ត្រឬអ្នកជំនួយវេជ្ជសាស្ត្រមួយរូប មានសិទ្ធិសុំបើកសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ឬជំនួយវេជ្ជសាស្ត្រឯកជនរបស់ខ្លួនបានតែមួយកន្លែង ទោះជាអ្នកនោះមានសញ្ញាប័ត្រឯកទេសច្រើនក៏ដោយ ។

## មាត្រា ៩.-

បែបបទនិងល័ក្ខខ័ណ្ឌនៃការសុំបើក សុំកែទ្រង់ទ្រាយ សុំបិទ ព្រមទាំងល័ក្ខខ័ណ្ឌបច្ចេកទេសនៃសេវាវេជ្ជសាស្ត្រ សេវាអមវេជ្ជសាស្ត្រនិងសេវាជំនួយវេជ្ជសាស្ត្រឯកជនត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី៣
## សមត្ថកិច្ចក្នុងការគ្រប់គ្រងនិងការត្រួតពិនិត្យ

**មាត្រា ១០.-**

ការណែនាំ ការគ្រប់គ្រង ការត្រួតពិនិត្យរាល់សកម្មភាពនៃវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ជំនួយដោយគណៈ-វិជ្ជាជីវៈសមស្របតាមក្រមសីលធម៌ តាមមុខវិជ្ជាជីវៈនីមួយៗ ។

ការរៀបចំនិងប្រព្រឹត្តទៅរបស់គណៈវិជ្ជាជីវៈនីមួយៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

បទប្បញ្ញត្តិស្តីពីក្រមសីលធម៌តាមមុខវិជ្ជាជីវៈនីមួយៗត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១១.-**

ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មត្រូវហាមឃាត់ជាដាច់ខាត លើកលែងតែការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ ដែលមិនប៉ះពាល់ដល់ក្រមសីលធម៌ហើយត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ១២.-**

ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ ត្រូវឋិតនៅក្រោមរបបនីតិរួមអំពីពន្ធនិងអាករ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៣.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ដល់៥.០០០.០០០(ប្រាំលាន)រៀល និងផ្អាកដំណើរការសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជ-

សាស្ត្រ ពី ១ខែទៅ ៣ខែ ឬទោសណាមួយក្នុងចំណោមទោសទាំងពីរនេះដោយពុំទាន់គិតពីបទល្មើសផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ មាត្រា ៦ មាត្រា ៧ មាត្រា ៨ មាត្រា ១១ ឬមាត្រា ១២ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេមួយជាពីរនិងផ្អាកដំណើរការសេវាឬបញ្ឈប់ជាស្ថាពរ ។

មាត្រា ១៤.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ដល់១០.០០០.០០០ (ដប់លាន)រៀល ចំពោះជនណាដែលរារាំងមិនឱ្យភ្នាក់ងារមានសមត្ថកិច្ចបំពេញភារកិច្ចអធិការកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ១០ ខាងលើ ។

មាត្រា ១៥.-

ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ១៣ ឬ១៤ ចំពោះមន្ត្រីរាជការ ឬជនណាដែលបានឃុបឃិត ឬប្រព្រឹត្តរំលោភលើភារកិច្ចរបស់ខ្លួន ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

មាត្រា ១៦.-

ក្នុងរយៈពេល ៦(ប្រាំមួយ)ខែយ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមានអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រឯកជន ដែលក្រសួងសុខាភិបាលបានចេញលិខិតអនុញ្ញាតឱ្យបើកសេវាជាផ្លូវការហើយនោះ ត្រូវបំពេញបន្ថែមនូវទំរង់បែបបទឱ្យត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។៚

រាជធានីភ្នំពេញថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

ហត្ថលេខា

ហុង ស៊ុនហួត

លេខ : ២១៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី [illegible] ខែវិច្ឆិកា ឆ្នាំ២០០០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់